## ៨-១-២  បុណ្យទក្ខិណានុប្បទាន

បុណ្យទក្ខិណានុប្បទានតាមទម្លាប់អ្នកស្រុកហៅថា“**បុណ្យតារ**”ព្រោះសម័យបុរាណព្រះសង្ឃដែលនិមន្តសូត្រក្នុងពេលនោះ តែងសូត្រ“ធម៌ពិស្តារ”ដល់ហៅកាត់តែអក្សរមួយតួខាងចុងថា “ធម៌តារ” ។

បុណ្យតារ (*) គេធ្វើដោយវេរចង្ហាន់ប្រគេនព្រះសង្ឃ ឧទ្ទិសផលបញ្ជូនទៅបុគ្គលដែលស្លាប់ ។

បុណ្យនេះគេតែងធ្វើនៅពេលដែលបុគ្គលជាញាតិមាន មាតា បិតាជាដើម ទើបនឹងស្លាប់ថ្មីៗ ឬ រាល់ឆ្នាំទៅមុខទៀត គឺធ្វើ១ខួបម្តង ចំលើថ្ងៃដែលបុគ្គលនោះស្លាប់ ។

ពិធីបុណ្យចាប់ពីម៉ោង ១០ ព្រឹកទៅ មាន ៖

១-នមស្សការ ព្រះរតនត្រ័យ

២-សមាទានសីល

៣-វេរភត្ត (មតកភត្ត) ដោយអាចារ្យ

៤-ប្រគេនចង្ហាន់និង ទេយ្យទានដល់ព្រះសង្ឃ ដោយអ្នកផ្តើមបុណ្យ,

៥-ព្រះសង្ឃបង្សុកូលសូត្រកត្តានុមោទនា តាមទម្លាប់ ដែលធ្លាប់សូត្រ,

៦-កិច្ចឧទ្ទិសផល (សូត្រ យំ កិញ្ចិ... ) ដោយឧបាសកឧបាសិកានិងអ្នកផ្តើមបុណ្យ ៕

----------------------------------------------------------

(*) ពីបូរាណ បើតារ គេមិនបាច់វេរទេ

វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។